# ពាក្យពេចន៍ចុងក្រោយ

ជូនចំពោះសិស្សានុសិស្សជាទីស្រលាញ់

យើងសង្ឃឹមថាការសិក្សានេះ នឹងធ្វើឱ្យអ្នកគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់។ បន្ទាប់ពីការសិក្សាមេរៀន និងការឆ្លើយសំណួរទាំងអស់មក តើអ្នកបានឆ្លល់ថា "តើខ្ញុំពិតជាគ្រិស្តបរិស័ទឬ? តើខ្ញុំស្គាល់ព្រះជាម្ចាស់ដែរឬទេ? តើទ្រង់ពិតជាគង់នៅក្នុងជីវិតខ្ញុំដែរឬទេ?" យើងចង់ផ្តល់ឱកាសឱ្យអ្នកនៅពេលនេះ ដើម្បីមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

យើងទាំងអស់គ្នាតែងតែមានកំហុស។ យើងបានធ្វើឱ្យខ្លួនឯង និងអ្នកដ៏ទៃឈឺចាប់។ ព្រះគម្ពីរបានហៅកិច្ចការនោះថាជាអំពើបាប ហើយយើងទាំងអស់គ្នាមានទោសកំហុសៈ " គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" ( រ៉ូម ៣:២៣)។ អំពើបាបរបស់យើងបានរារាំងយើងមិនឱ្យស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះវរបិតា។ ក៏ប៉ុន្តែ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងយើង ថ្វីបើយើងមានអំពើបាបក៏ដោយ។ " ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ" ( យ៉ូហាន ៣:១៦)។ ព្រះយេស៊ូបានទទួលយកទារុណកម្ម ដែលយើងសមនឹងទទួលសម្រាប់អំពើបាបរបស់យើង នៅពេលដែលទ្រង់បានសុគត។

តើអ្នកចង់ឱ្យប្រាកដថា ព្រះយេស៊ូជាព្រះសង្គ្រោះអ្នកដែរឬទេ? វាពិតជាសាមញ្ញណាស់៖

- ចូរទទួលស្គាល់ថាអ្នកជាមនុស្សមានបាប ដែលបានដាច់ចេញពីព្រះជាម្ចាស់ ហើយទូលសូមឱ្យព្រះអង្គអត់ទោសឱ្យ។
- ចូរជឿលើព្រះយេស៊ូឱ្យអស់ពីចិត្ត ហើយឱ្យទ្រង់ជ្រាបថា អ្នកបានទទួលព្រះអង្គជាព្រះសង្គ្រោះរបស់អ្នក។

អ្នកអាចនិយាយទៅកាន់ព្រះជាម្ចាស់ដោយពាក្យរបស់អ្នកផ្ទាល់ ដោយនិយាយនូវសេចក្តីអធិស្ឋានដូចនេះ៖
*ឱព្រះយេស៊ូអើយទូលបង្គំដឹងថាទូលបង្គំជាមនុស្សមានបាប។ សូមអត់ទោសដល់ទូលបង្គំផង។ ទូលបង្គំជឿថាទ្រង់ជាព្រះរាជបុត្រាដ៏នៅអស់កល្បរបស់ព្រះជាម្ចាស់។ អរគុណព្រះអង្គ សម្រាប់ការសុគតនៅលើឈើឆ្កាងជំនួសអំពើបាបរបស់ទូលបង្គំ។ សូមយាងមកគង់ក្នុងជីវិតរបស់ទូលបង្គំ។ សូមធ្វើការនៅក្នុងជីវិតរបស់ទូលបង្គំ។ សូមធ្វើជាព្រះអម្ចាស់របស់ទូលបង្គំនៅថ្ងៃនេះ។ អរគុណព្រះអង្គដែលបានសង្គ្រោះទូលបង្គំ! អាម៉ែន។*

ប្រសិនជាអ្នកបានអធិស្ឋាននូវសេចក្តីអធិស្ឋាននេះ ហើយធ្វើវាឱ្យអស់ពីចិត្ត អំពើបាបរបស់អ្នក នឹងទទួលបាននូវការអត់ទោស ហើយអ្នកនឹងទទួលបានជីវិតអស់កល្បជានិច្ច។ ព្រះយេស៊ូ ជាព្រះអម្ចាស់នៃជីវិតរបស់អ្នក។ ព្រះគម្ពីរបានប្រាប់ថា " ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងអោយបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (១យ៉ូហាន ១:៩)។

សូមស្វាគមន៍ការចូលរួមក្នុងគ្រួសាររបស់ព្រះជាម្ចាស់។ យើងមានអំណរជាមួយអ្នក ដូច្នេះ សូមសរសេរ និងប្រាប់យើងពីអ្វីដែលព្រះជាម្ចាស់បានធ្វើក្នុងជីវិតរបស់អ្នក។

សូមព្រះជាម្ចាស់ប្រទានពរដល់អ្នក!

………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………

ឈ្មោះ……………………………………………………………………………………………

## តើអ្នកមានមិត្តភ័ក្តិដែលត្រូវការស្គាល់បន្ថែមអំពីព្រះយេស៊ូដែលឬទេ?

សូមផ្ញើឈ្មោះ និងអាសយដ្ឋានមិត្តភក្តិរបស់អ្នកសម្រាប់ចម្លើយដ៏អស្ចារ្យនៃជីវិតរបស់អ្នក។

ឈ្មោះ……………………………………………………………………………………………

អាសយដ្ឋាន………………………………………………………………………………………

………………………………………………………………………………………………………